# តារាងសម្ពង្សនាគ




## ដណ្ដឹងគូរ

+ដើម្បីផ្សំផ្គុំបុត្រ និងបុត្រធីតាឱ្យបានគ្នាជាប្ដី-ប្រពន្ធគ្រប់ថៃរក្សាគ្នាឱ្យបានសុខសាន្ត សំប្បូរ សប្បាយ ប្រកបដោយសុភមង្គលគ្រប់ប្រការ គួរជ្រើសរើសសម្ពង្សគូរទាំងពីរឱ្យបានល្អប្រសើរ តាមរបៀបខាងក្រោមនេះ :

+បើប្រុស លោកឱ្យរាប់លេខ ១ ត្រង់ក្បាលនាគ រៀងរហូតដល់ចុងកន្ទុយនាគ លេខ១២ ។

+បើស្រី លោកឱ្យរាប់ពីលេខ ១២ ត្រង់កន្ទុយនាគ ច្រាសមកខាងក្បាលវិញ ។

+បើរាប់ឆ្នាំកំណើតអ្នកទាំងពីរ ទៅត្រូវលើលេខរៀងណា ឬខុសក្រឡាពីគ្នា ឱ្យពិចារណាតាម បេបនេះចុះ ។

១-បើឆ្នាំអ្នកទាំងពីរចាប់ទៅត្រូវលើលេខ ១ ក្បាលនាគតែមួយ ខ្លួនជាមួយគ្នា ទាយថាល្អណាស់ នឹងអាចនៅរួមរស់ជាមួយគ្នាបានសុខសាន្ត ថៃរក្សាគ្នាបានរហូត លុះចាស់រៀង១ខ្លួន ។

២-បើត្រូវត្រង់កន្ទុយនាគទាំងពីរ ខ្លួនជាមួយគ្នា ទាយថាល្អណាស់ អាចរក្សាគ្នាបាន រកស៊ីកើតកាលវាលគុម្ព ទ្រព្យសម្បត្តិហូរចូល រស់នៅជាមួយគ្នានឹងបានសុខ និងបានកូនចៅជាទីស្រឡាញ់ ។

៣-បើត្រូវត្រង់កណ្ដាលខ្លួនទាំងពីរ ខ្លួននាគតែមួយ ទាយថាល្អប្រសើរណាស់ មានចិត្តស្មោះត្រង់ នឹងគ្នាចេះស្រឡាញ់គោរពគ្នាទៅវិញទៅមក ។

៤-បើត្រូវត្រង់ក្បាលនាគ និងកន្ទុយ រួមខ្លួតែមួយ ទំនាយថា ល្អបង្គួរ ។

៥-បើត្រង់ក្បាលនាគទាំងពីរ តែខ្លួនផ្សេងគ្នា ទំនាយថា អាក្រក់ណាស់ នឹងត្រូវព្រាត់ប្រាសគ្នា រកស៊ីពុំបានលាភផលអ្វីឡើយ ។

៦-បើត្រូវត្រង់កន្ទុយទាំងពីរ ខ្លួនផ្សេងពីគ្នា មិនល្អឡើយ ។

៧-បើត្រូវត្រង់កណ្តាលខ្លួននាគ ខ្លួនផ្សេងពីគ្នា ទំនាយថា អាក្រក់ណាស់ ថែរក្សាគ្នាពុំបាន ឡើយ ។

៨-បើត្រូវត្រង់ក្បាលនាគក្តី កណ្តាលខ្លួនក្តី ឬក៏កន្ទុយនាគក្តី ខ្លួនផ្សេងពីគ្នា ទំនាយថា អាក្រក់ ណាស់គួរកុំភពប្រសព្វឡើយ ។